*Press Office*
**U.S. Department of Homeland Security**
500 C Street, SW
Washington, DC 20472

FEMA

# សេចក្តីប្រកាសពត៌មាន

ថ្ងៃទី ៦ ខែតុលា ឆ្នាំ២០០៦
លេខ : ០៦-១៤២ (06-142)
ទាក់ទង: មន្ត្រីពត៌មាន នៃ ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ (FEMA)
(២០២) ៦៤៦-៤៦០០

## រថសណ្តោងសំរាប់ជនពិការ
## អាចទាក់ទងទទួលយកបានពី ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ (FEMA)

រដ្ឋធានីវ៉ាស៊ីនតោន, ឌី.ស៊ី.- ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ (FEMA) កំពុងចាត់ចែងផែនការឧបត្ថម្ភនូវរថសណ្តោងសំរាប់ស្នាក់នៅបណ្តោះអាសន្ន ដល់ជនពិការ និងដល់គ្រួសារដែលមានសមាជិកជាជនពិការ ក្នុងចំណោមជនភៀសខ្លួនពីអាសន្នព្យុះហ៊ើរីខេន កាទ្រីណា និង រីតា ដើម្បីរួមចំណែកក្នុងដីការដែលបានសម្រេចលើពាក្យបណ្តឹង (**Brou v. FEMA**) ដោយ តុលាការ-សហព័ន្ធប្រចាំស្រុក ក្នុងស្រុកភាគខាងកើតនៃរដ្ឋលូហ្ស៊ីអាណា នៅថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០០៦ ។ ជនពិការក្នុងចំណោមជនភៀសខ្លួនពីអាសន្នព្យុះ កាទ្រីណា និង រីតា ដែលគ្មានទីលំនៅបណ្តោះអាសន្ន សូមទាក់ទងមក ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ (FEMA) ដើម្បីរាយការណ៍ពីតំរូវការផ្សេងៗរបស់ពួកគេ ទោះបីជាពួកគេធ្លាប់បានទាក់ទងជាមួយ ភ្នាក់ងារ គ្រប់គ្រងភាពអា-សន្នសហព័ន្ធ (FEMA) ពីមុនមកក្តី ។

ជនពិការ មានន័យថាជាជនដែលអសមត្ថភាពលើបុគ្គលិលក្ខណៈណាមួយដែលដាក់កំហិតដល់សកម្មភាព ក្នុងជីវិតរបស់គេដូចជា: ការដើរហើរ, ការមើល, ការស្តាប់, រឺការនិយាយ ។ ពួកគេអាចទាក់ទងដើម្បីទទួលយកនូវរថសណ្តោងពី ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ (FEMA)។ ពួកគេអាចទទួលបាននូវរថសណ្តោង ដែលមានបំពាក់នូវច្រកនិងកំណល់ធំល្មមសំរាប់កៅអីជនពិការ, អាងទឹកតូច រឺក្បាលទុយោផ្កាឈូកសំរាប់ងូតទឹក, បង្កាន់ដៃក្នុងបន្ទប់ទឹក, និងអាងទឹកតូចនៅក្បែរបង្គន់ អាស្រ័យលើស្ថានភាពរបស់ជនពិការ, បុគ្គលនិមួយៗ និង/រឺ ក្រុមគ្រួសារដែលពួកគេរស់នៅជាមួយ ។

ជនពិការ រឺជនដែលមានសមាជិកគ្រួសារជាជនពិការ ដែលត្រូវការរថសណ្តោង សូមទំនាក់ទំនងទូរស័ព្ទលេខ ១-៨៦៦-៤៩៦-៤២៩៧ (សំរាប់ជនភៀសខ្លួននៅលូហ្ស៊ីអាណា) និង ១-៨៨៨-២៩៤-២៨២០ (សំរាប់ជនភៀសខ្លួននៅមីស៊ីស៊ីពី) ពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ៦:០០ល្ងាចរៀងរាល់ថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍ (យើងក៏មានលេខ TTY ១-៨០០-៤៦២-៧៥៨៥ សំរាប់អ្នករស

-- មានត --

នៅទាំងរដ្ឋលូហ្ស៊ីអាណា និងរដ្ឋមីស៊ីស៊ីពី) ។ សំរាប់អ្នកដែលទូរស័ទ្ទតាមរយៈលេខថ្លលហ្វ្រី សូមត្រៀមចំគំនិតផ្សេងៗដើម្បីពិភាក្សាទាក់ទិននឹងពិការភាព និងរាល់តំរូវការផ្សេងៗដែលអ្នកត្រូវការ ។

ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ (FEMA) នឹងជួយដល់បុគ្គល ដែលជាជនពិការនិមួយៗ តាមរយៈការផ្តល់ រថសណ្តោង, ពិនិត្យ និងផ្លាស់រថសណ្តោង ដែលជនពិការមានស្រាប់ រឺស្វែងរកទីកន្លែងសមរម្យសំរាប់អ្នកដែលត្រូវការទីជំរក ។

អាចចំណាយពេលអស់ ៩០ថ្ងៃ ដើម្បីទទួលបានតាមសំណើសុំរថសណ្តោង រឺអាចចំណាយពេលយូរជាងពេលកំណត់ខាងលើ ប្រសិនបើអ្នកស្នើសុំពុំមានទីតាំងត្រឹមត្រូវសំរាប់រក្សារថសណ្តោង ។ អាចចំណាយពេលអស់ ៦០ថ្ងៃ ដើម្បីទទួលបានការសំរេចលើសំណើ សុំផ្លាស់ប្តូររថសណ្តោងដែលមានស្រាប់ ។

**ទំព័រទី២- រថសណ្តោងដែលអាចស្នើសុំបានពី ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ(FEMA)**

ជនពិការដែលមិនទាន់មានរថសណ្តោងសំរាប់ស្នាក់នៅ សូមទាក់ទងភ្នាក់ងាររបស់យើងតាមរយៈលេខ ១-៨៦៦-៤៩៦-៤២៩៧ (សំរាប់ជនភៀសខ្លួននៅលូហ្ស៊ីអាណា) និង ១-៨៨៨-២៩៤-២៨២០ (សំរាប់ជនភៀសខ្លួននៅមីស៊ីស៊ីពី) ។ ដើម្បីទទួលបាននូវរថសណ្តោងក្នុងអំឡុងពេលកំណត់ខាងលើ សូមលោកអ្នកទំនាក់ទំនង ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ(FEMA) អោយបានមុន ថ្ងៃទី ៩ ខែឧសភា ឆ្នាំ ២០០៧ ។

ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ(FEMA) គ្រប់គ្រងគំរោងសហព័ន្ធសំរាប់ការសង្គ្រោះ និងឆ្លើយតបទៅ នឹងឧប្បត្តិហេតុកំរិតជាតិ ។ ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ(FEMA) ក៏បានបង្កើតនូវសកម្មភាព សម្របសម្រួលផ្សេងៗ ដើម្បីធ្វើការរួមជាមួយនឹងប្រធានកម្មវិធីគ្រប់ភាពអាសន្នថ្នាក់មូលដ្ឋាន និងថ្នាក់រដ្ឋ និង គ្រប់គ្រងកម្មវិធីធានារ៉ាប់ទឹកជំនន់ជាតិ ។ ភ្នាក់ងារគ្រប់-គ្រងភាពអាសន្នសហព័ន្ធ(FEMA) បានក្លាយជាភ្នាក់ងារចំណុះ នាយកដ្ឋានសន្តិសុខមាតុភូមិ នៅថ្ងៃទី ១ ខែមិនា ឆ្នាំ ២០០៣ ។

###

**កំណត់ចំណាំសំរាប់អ្នកផលិតៈ** លោកអ្នកអាចថតចំលង(download) ឯកសារ កំណែ MP3 (MP3 Versions) របស់ PSAs ជាភាសារអង់គ្លេស និង ភាសារអេស្ប៉ាញ ដែលបានផលិតដោយ ភ្នាក់ងារគ្រប់គ្រងភាពអាសន្នសហព័ន្ធ (FEMA) តាមរយៈគេហទំព័រៈ www.fema.gov/radio